**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...០០២...............សហវ-ខគ៣ព

ថ្ងៃសុក្រ ៣ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០២០

# សារាចរណែនាំ
## ស្តីពី
## ការលើកលែងពន្ធលើប្រាក់បំណាច់អតីតភាពការងារចាប់ពីឆ្នាំ២០២០

អនុលោមតាមប្រកាសលេខ ០៩៨ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ស្តីពីពន្ធលើប្រាក់ចំណូល, ប្រកាសលេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់បៀវត្ស, ប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ និងសារាចរណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ ស្តីពីការលើកលែងពន្ធលើប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ និងប្រាក់បំណាច់អតីតភាពការងារចាប់ពីឆ្នាំ២០១៩តទៅមុខ និងសេវារកការងារធ្វើ បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករឬកម្មសិក្សាការីទៅធ្វើការនៅបរទេស ក្នុងគោលបំណងចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់កម្មករនិយោជិតនៅតាមបណ្តាសហគ្រាសនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចខាងក្រោម÷

១- លើកលែងពន្ធលើប្រាក់បៀវត្សចំពោះប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ និងប្រាក់បំណាច់អតីតភាពការងារក្នុងឆ្នាំ២០១៩ របស់កម្មករនិយោជិតជាជនជាតិខ្មែរ នៃផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង និងផ្នែកដទៃទៀត ដោយត្រូវអនុវត្តតាមសារាចរណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ ស្តីពីការលើកលែងពន្ធលើប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ និងប្រាក់បំណាច់អតីតភាពការងារចាប់ពីឆ្នាំ២០១៩ តទៅមុខ និងសេវារកការងារធ្វើ បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករឬកម្មសិក្សាការីទៅធ្វើការនៅបរទេស។

២- ចំពោះប្រាក់បំណាច់អតីតភាពការងារចាប់ពីឆ្នាំ២០២០ របស់កម្មករនិយោជិត នៃផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង និងផ្នែកដទៃទៀត ត្រូវអនុវត្តដូចខាងក្រោម÷

ក- លើកលែងពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បំណាច់អតីតភាពការងារ ដែលមានទឹកប្រាក់មិនលើសពី ៤ ០០០ ០០០ រៀល ក្នុងមួយឆ្នាំ

ខ- ចំពោះប្រាក់បំណាច់អតីតភាពការងារដែលមានទឹកប្រាក់លើសពី ៤ ០០០ ០០០ រៀលក្នុងមួយឆ្នាំ ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស។ ក្នុងករណីដែលប្រាក់បំណាច់អតីតភាពការងារត្រូវបើកក្នុងមួយឆ្នាំ ២ដង ការគណនាពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បំណាច់អតីតភាពការងារ ត្រូវអនុវត្តដូចខាងក្រោម÷

- ការបើកប្រាក់បំណាច់លើកទី១÷ ត្រូវយកចំនួនទឹកប្រាក់បំណាច់ដែលត្រូវទទួល ដក ២ ០០០ ០០០ រៀល ហើយចំនួននៅសល់ត្រូវបូកបញ្ចូលទៅក្នុងមូលដ្ឋានប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ដែលប្រាក់បំណាច់ត្រូវបានបើក



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

- ការបើកប្រាក់បំណាច់លើកទី២÷ ត្រូវអនុវត្តដូចការបើកប្រាក់លើកទី១ ដែរ ដោយត្រូវយកចំនួនទឹកប្រាក់បំណាច់ដែលត្រូវទទួលលើកទី២ ដក ២ ០០០ ០០០ រៀល ហើយចំនួននៅសល់ត្រូវបូកបញ្ចូលទៅក្នុងមូលដ្ឋានប្រាក់បៀវត្សជាប់ពន្ធប្រចាំខែដែលប្រាក់បំណាច់ត្រូវបានបើក។

៣- ចំណាយលើការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលមានការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។

ទទួលបានសារាចរនេះ អគ្គនាយកដ្ឋានពន្ធដារ គ្រប់អង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័នពាក់ព័ន្ធ រោងចក្រ សហគ្រាស ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពនិងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សាលារាជធានី-ខេត្ត